-លើកគំរោងសកម្មភាព កម្មវិធី គម្រោងការ ដើម្បីអនុវត្តការងារគ្រប់គ្រងគ្រោះមហន្តរាយនៅកម្ពុជា ។

-ពិនិត្យផ្តល់យោបល់ការងារបច្ចេកទេសគ្រប់គ្រងគ្រោះមហន្តរាយរបស់ក្រសួងពាក់ព័ន្ធ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ខេត្ត-ក្រុង និងក្រុមសាជីវកម្ម ។

-ឧបត្ថម្ភផ្នែកបច្ចេកទេស និងជូនយោបល់លើសំណើកំណត់ការប្រកាសអាសន្នថ្នាក់ជាតិរបស់អគ្គលេខាធិការដ្ឋាន "គ.ជ.គ.ម" ។

ប្រការ ៣ : សមាជិកតំណាងអោយក្រសួងពាក់ព័ន្ធនីមួយៗ ត្រូវទទួលខុសត្រូវក្នុងក្របខ័ណ្ឌសមត្ថកិច្ច ភារកិច្ចដែលបានកំណត់ក្នុងមាត្រា២ និងត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន "គ.វ.ក." ។

ប្រការ ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះ ចាប់តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

ឧបនាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ស ខេង

★★★

រាជធានីភ្នំពេញ,ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០០

## សេចក្តីសំរេច លេខ ០៨ សសរ

## ស្តីពី ការបង្កើត

## គណៈកម្មការអន្តរក្រសួង ចុះពិនិត្យទីតាំងសំណង់អនាធិបតេយ្យ

## នៅភ្នំព្រះរាជទ្រព្យ (ភ្នំឧត្តុង្គ)

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខនស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-យោងតាមសំណើរបស់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

**សំរេច**

ប្រការ ១ : បង្កើតគណៈកម្មការអន្តរក្រសួង ចុះពិនិត្យទីតាំងសំណង់អនាធិបតេយ្យនៅភ្នំព្រះរាជទ្រព្យ(ភ្នំឧត្តុង្គ) ដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-ឯកឧត្តម ឌី យ៉ាទ | រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ប្រធាន |
| ២-ឯកឧត្តម ទ្រាំ សុខា | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣-ឯកឧត្តម ជុច ធឿន | អនុរដ្ឋលេខាធិការ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | សមាជិក |
| ៤-ឯកឧត្តម ដោក ណារិន | អនុរដ្ឋលេខាធិការក្រសួងធម្មការនិងកិច្ចការសាសនា | សមាជិក |
| ៥-ឯកឧត្តម ទឹម ម៉ានី | អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ៦-ឯកឧត្តម ហ៊ុល លីម | អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៧-ឯកឧត្តម ជ័យ សម្បូណ៌ | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ៨-ឯកឧត្តម ឈុន សារិត | អនុអនុលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៩-ឯកឧត្តម ឃឹម មុ | អភិបាលរងទី១ ខេត្តកណ្ដាល | សមាជិក |
| ១០-លោក កែវ ធីទុង | តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១១-លោកអភិបាលស្រុកពញាឮ | | សមាជិក |
| ១២-មន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | | លេខាធិការ |

ប្រការ ២ : គណៈកម្មការមានភារកិច្ច :

-សិក្សានិងកំណត់តំបន់បេតិកភ័ណ្ឌប្រវត្តិសាស្ត្រភ្នំព្រះរាជទ្រព្យ (ភ្នំឧត្តុង្គ) ។

-ផ្អាករាល់សកម្មភាពសាងសង់នានា ហើយរង់ចាំការដោះស្រាយរបស់គណៈកម្មការ លើកលែងតែសំណង់បូជនីយដ្ឋានសំរាប់តំកល់ព្រះសិរីរិក្ខធាតុ ។

-ផ្អាកការអនុវត្តន៏ និងពិនិត្យឡើងវិញនូវសេចក្ដីសំរេចលេខ ២៥៤ កធត ចុះថ្ងៃទី ១៧-១១-៩៩ របស់ក្រសួងធម្មការ និងកិច្ចការសាសនា ។

-ពិនិត្យនិងលើកវិធានការដោះស្រាយជាបន្ទាន់ អំពីទីតាំងសំណង់អនាធិបតេយ្យ នៅភ្នំព្រះរាជទ្រព្យ (ភ្នំឧត្តុង្គ)

-រាយការណ៍ អំពីលទ្ធផលការងារនេះ ជូនរាជរដ្ឋាភិបាល ។

ប្រការ ៣ : គណៈកម្មការនេះមានការិយាល័យអចិន្ត្រៃយ៍ តាំងនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងមានសិទ្ធប្រើប្រាស់ត្រារបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

ប្រការ ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងធម្មការ និងកិច្ចការសាសនា អភិបាលខេត្តកណ្តាល មានភារកិច្ចអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

## III- ការងារបណ្តាក្រសួង

### ទីស្តីការរដ្ឋមន្ត្រី ក្រសួងអប់រំយុវជន និងកីឡា

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០០

### ប្រកាស

### ប្រកាសលេខ ១៩១ អយក-ប្រក

### ស្តីការផ្ទាច់សាលាឧបសម្ព័ន្ធ "ព្រែកតាគង់" មកជាសាលាបឋមសិក្សា ពេញលក្ខណៈ

****

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញអនុក្រឹត្យលេខ៦១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង អប់រំយុវជន និងកីឡា

-បានឃើញលិខិតស្នើសុំរបស់ប្រធានមន្ទីរអប់រំយុវជន និងកីឡា រាជធានីភ្នំពេញ លេខ១០៣ មសៈបារ ចុះថ្ងៃទី០៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៩

-តាមយោបល់ឯកភាពរបស់នាយកដ្ឋានបឋម និងមត្តេយ្យសិក្សា